# ជំងឺ COVID-19

## នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles
## សំណួរដែលបានសួរជាញឹកញាប់ (FAQ) ទីតាំងមើលថែទាំកុមារលក្ខណៈគ្រួសារ

## សំណួរដែលបានសួរជាញឹកញាប់

### 1. តើខ្ញុំត្រូវរាយការណ៍ទៅនាយកដ្ឋានសុខភាពសាធារណៈ (DPH) នៃខោនធី Los Angeles នៅពេលណា និងដោយរបៀបណា?

- សូមរាយការណ៍ ប្រសិនបើអ្នកបានរកឃើញករណីនៃជំងឺ **COVID-19 ដែលបានបញ្ជាក់ពីមន្ទីរពិសោធន៍** (ករណីវិជ្ជមានច្បាស់លាស់) ចំនួន 1 ឡើងទៅ ដែលបានទៅកន្លែងមើលថែទាំកុមារ នៅពេលណាមួយក្នុងអំឡុងពេល 14 ថ្ងៃមុនកាលបរិច្ឆេទចាប់ផ្តើមមានជំងឺ (កាលបរិច្ឆេទចាប់ផ្តើមមានជំងឺគឺជាថ្ងៃខែដំបូងដែលមានរោគសញ្ញានៃជំងឺ COVID-19 ឬថ្ងៃខែនៃការធ្វើតេស្តរកជំងឺ COVID-19 យកចំណុចណាមួយដែលកើតឡើងមុន)។ អ្នកដែលឆ្លងមេរោគអាចជាសមាជិករបស់បុគ្គលិក កុមារម្នាក់ សមាជិកគ្រួសាររបស់អ្នក ឬអ្នកមកលេងនៅទីតាំងរបស់អ្នក។
- ការរាយការណ៍តាមអនឡាញដែលមានសុវត្ថិភាព គឺជាវិធីដ៏ល្អបំផុតដើម្បីជូនដំណឹងដល់ DPH នៃការប៉ះពាល់នឹងជំងឺ COVID-19។ វាអាចធ្វើឡើងបាននៅលើកុំព្យូទ័រ ឬឧបករណ៍ចល័តដោយអាចចូលប្រើកម្មវិធីតាមបណ្តាញដែលមានសុវត្ថិភាព។ អ្នកអាចទាញយកសំណុំបែបបទនេះដោយចូលទៅកាន់គេហទំព័រ http://www.redcap.link/lacdph.educationsector.covidreport។
- ប្រសិនបើអ្នកមិនអាចបំពេញបែបបទបានទេ សូមទាញយកហើយបំពេញ តារាងបញ្ជីករណីនិងអ្នកដែលមានទំនាក់ទំនងនឹងជំងឺ COVID-19 សម្រាប់វិស័យអប់រំ ហើយផ្ញើទៅតាមអាសយដ្ឋានអ៊ីម៉ែលនេះ ACDC-Education@ph.lacounty.gov។ ចូរពិនិត្យមើលការណែនាំអំពីការការពារដោយពាក្យសម្ងាត់នៅចុងបញ្ចប់នៃឯកសារនេះ ដើម្បីស្វែងយល់ពីរបៀបការពារឯកសារ មុនពេលផ្ញើតាមអ៊ីម៉ែលទៅ។
- ប្រសិនបើការចូលប្រើកុំព្យូទ័រ និង/ឬអ៊ិនធរណេតសម្រាប់ការរាយការណ៍គឺជាបញ្ហាពិបាក សូមទូរស័ព្ទទៅកាន់លេខ 888-397-3993។
- រាល់ការជូនដំណឹងអំពីករណីទាំងអស់ គួរតែត្រូវបានបញ្ជូនទៅក្នុងរយៈពេល 1 ថ្ងៃធ្វើការ បន្ទាប់ពីអ្នកបានដឹងអំពីករណីនេះ។
- ប្រសិនបើអ្នកមានសំណួរពាក់ព័ន្ធនឹងការប៉ះពាល់នៃមេរោគ ឬរំពឹងថា ត្រូវការពេលវេលាច្រើនជាង 1 ថ្ងៃធ្វើការ ដើម្បីបំពេញបញ្ជីឈ្មោះនោះ អ្នកអាចអ៊ីម៉ែលទៅកាន់អាសយដ្ឋាន ACDC-Education@ph.lacounty.gov ដើម្បីស្នើសុំការពន្យាលពេល។ អ្នកត្រូវតែបំពេញ និងដាក់បញ្ជូនតារាងបញ្ជីករណីនិងអ្នកដែលមានទំនាក់ទំនងនេះឱ្យបានកាន់តែឆាប់កាន់តែល្អ។
- ប្រសិនបើអ្នកបានរកឃើញករណីនៃជំងឺ COVID-19 ច្បាស់លាស់ចំនួន 3 ឡើងទៅ ក្នុងអំឡុងពេល 14 ថ្ងៃ អ្នកតម្រូវឱ្យរាយការណ៍**ជាបន្ទាន់** ដោយអនុវត្តតាមជំហានរាយការណ៍ខាងលើ។

### 2. តើខ្ញុំដឹងថា អាចនឹងមានការប៉ះពាល់មេរោគនៅឯកន្លែងថែទាំកុមារលក្ខណៈគ្រួសាររបស់ខ្ញុំយ៉ាងដូចម្តេច?

ប្រសិនបើករណីវិជ្ជមាននោះ (ទាំងជនណាម្នាក់ដែលមានលទ្ធផលតេស្តវិជ្ជមានសម្រាប់ជំងឺ COVID-19 ឬអ្នកដែលបានទទួលការពិនិត្យដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ពួកគេថា មានជំងឺ COVID-19 ក៏ដោយ) **បាននៅ**ក្នុងទីតាំងមើលថែទាំកុមារលក្ខណៈគ្រួសារក្នុង***អំឡុងពេលដែលអាចចម្លងមេរោគ***របស់ពួកគេបាននោះ គឺមានការប៉ះពាល់នៅទីកន្លែងរបស់អ្នកហើយ។

- រយៈពេលដែលអាចចម្លងមេរោគបាន (អំឡុងពេលដែលករណីនេះអាចចម្លងទៅដល់អ្នកដទៃ) ត្រូវបានកំណត់ថាជាចំណុចណាមួយចាប់ពី ពីរថ្ងៃមុនពេលរោគសញ្ញារបស់ពួកគេចាប់ផ្តើមលេចចេញ រហូតដល់យ៉ាងហោចណាស់ 10 ថ្ងៃបានកន្លងផុតទៅ ចាប់តាំងពីពេលរោគសញ្ញារបស់ពួកគេបានចាប់ផ្តើមលេចចេញ ហើយពួកគេមិនមានគ្រុនក្តៅយ៉ាងហោចណាស់ 24 ម៉ោង (ដោយមិនប្រើថ្នាំដើម្បីបន្ថយកម្តៅ) និងរោគសញ្ញានានារបស់ពួកគេបានធូរស្បើយ។
- ប្រសិនបើអ្នកដែលឆ្លងមេរោគមិនមានរោគសញ្ញានោះទេ រយៈពេលដែលអាចចម្លងមេរោគបានត្រូវបានកំណត់ថា ពីរថ្ងៃមុនពេលពួកគេបានធ្វើតេស្ត និងរាប់រហូតរយៈពេល 10 ថ្ងៃបន្ទាប់ពីនោះមក។

ប្រសិនបើបុគ្គលនោះ**មិនបាននៅ**ក្នុងទីតាំងថែទាំកុមារក្នុងអំឡុងពេលដែលអាចចម្លងមេរោគរបស់ពួកគេបាននោះទេ ទីតាំងថែទាំកុមារមិនមានការប៉ះពាល់ឡើយ។ ទោះជាយ៉ាងណាក៏ដោយ ដូចដែលបានកត់សម្គាល់ខាងលើ ទីតាំងថែទាំកុមារនេះនៅតែត្រូវបានតម្រូវឱ្យរាយការណ៍អំពីករណីច្បាស់លាស់ណាមួយ ប្រសិនបើអ្នកដែលឆ្លងមេរោគនេះស្ថិតនៅក្នុងទីកន្លែង និងនៅពេលណាមួយក្នុងអំឡុងពេល 14 ថ្ងៃមុនកាលបរិច្ឆេទចាប់ផ្តើមមានជំងឺ ទោះបីជាម្ចាស់ទីតាំងមើលថែទាំកុមារកំណត់ថា ការប៉ះពាល់មិនកើតឡើងក៏ដោយ។

## 3. តើខ្ញុំដឹងដោយរបៀបណាថា នៅពេលណាដែលអាចចាត់ទុកថានរណាម្នាក់ជាបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធ (បានប៉ះពាល់) ទៅនឹងករណីជំងឺ COVID-19?

ជនណាម្នាក់ត្រូវបានចាត់ទុកថាជាបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធ* ប្រសិនបើពួកគេមានការប៉ះពាល់តាមវិធីណាមួយទៅនឹងបុគ្គលដែលបានពិនិត្យឃើញថាមានជំងឺ COVID ក្នុងអំឡុងពេលដែលអាចចម្លងមេរោគបាន៖

- ពួកគេបានស្ថិតនៅក្នុងបរិវេណ 6 ហ្វីតរយៈពេលសរុប 15 នាទីឡើងទៅក្នុងអំឡុងពេល 24 ម៉ោង **ឬ**
- ពួកគេមានការប៉ះពាល់ជាមួយនឹងវត្ថុរាវ និង/ឬសារធាតុបញ្ចេញនៃរាងកាយផ្សេងៗ ពីអ្នកដែលមានជំងឺ COVID-19 ដោយមិនបានការពារ។ ឧទាហរណ៍ ពួកគេត្រូវបានបុគ្គលដែលមានផ្ទុកមេរោគនេះក្អកឬកណ្តាស់ដាក់ ឬបានប្រើពែងទឹកឬប្រដាប់បរិភោគអាហាររួមគ្នា ឬបានផ្តល់ការថែទាំដល់ពួកគេដោយមិនបានពាក់ឧបករណ៍ការពារត្រឹមត្រូវ។

ប្រសិនបើបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធនេះបានចាក់ថ្នាំបង្ការពេញលេញ ហើយមិនមានរោគសញ្ញាទេ នោះពួកគេមិនចាំធ្វើចត្តាឡីស័កឡើយ។ ប្រសិនបើបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធនេះមិនបានចាក់ថ្នាំបង្ការពេញលេញទេ ពួកគេត្រូវតែអនុវត្តតាម សេចក្តីណែនាំសម្រាប់ការធ្វើចត្តាឡីស័ក។

* សេចក្តីណែនាំអំពី COVID-19 នៅក្នុងវិស័យអប់រំកំពុងផ្លាស់ប្តូរ។ ពិនិត្យឡើងវិញឱ្យបានទៀងទាត់នូវ ផែនការគ្រប់គ្រងការប៉ះពាល់នឹងមេរោគនៅក្នុងមណ្ឌលថែទាំនិងអប់រំកុមារតូច សម្រាប់និយមន័យនៃបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធដែលថ្មីបំផុត នៅក្នុងវិស័យអប់រំ។

## 4. តើមនុស្សម្នាក់ត្រូវបានគេចាត់ទុកថាទទួលថ្នាំបង្ការពេញលេញនៅពេលណា?

បុគ្គលម្នាក់ត្រូវបានចាត់ទុកថា បានចាក់ថ្នាំបង្ការពេញលេញប្រឆាំងជំងឺ COVID-19 គឺគិតចាប់ពី 2 សប្តាហ៍បន្ទាប់ពី៖

- ពួកគេបានចាក់ដូសតែមួយនៃថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Johnson & Johnson (J&J)/Janssen រួចរាល់ហើយ ឬ
- ពួកគេបានចាក់ដូសទីពីរនៃថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer ឬ Moderna  រួចរាល់ហើយ ឬ
- ពួកគេបានបញ្ចប់ការចាក់ជាលំដាប់នូវ ថ្នាំបង្ការ ជំងឺ COVID-19 ប្រភេទណាមួយដែលត្រូវបានចុះបញ្ជីអនុញ្ញាតឱ្យប្រើប្រាស់ជាបន្ទាន់ដោយអង្គការសុខភាពពិភពលោក (ឧទាហរណ៍ ថ្នាំបង្ការប្រភេទ AstraZeneca/Oxford និង Sinopharm)។

ប្រសិនបើមានរយៈពេលតិចជាង 2 សប្តាហ៍បន្ទាប់ពីការចាក់ដូសទីពីរ ឬដូសតែមួយរបស់ពួកគេ ពួកគេនឹងមិនមានការការពារពីមេរោគ COVID-19 គ្រប់គ្រាន់ដើម្បីបញ្ឈប់ជំហានក្នុងបង្ការជំងឺ ដោយសុវត្ថិភាពឡើយ។

សូមមើលគេហទំព័រ នៅពេលដែលអ្នកបានចាក់ថ្នាំបង្ការពេញលេញ សម្រាប់ព័ត៌មានបន្ថែម រួមទាំងការណែនាំនានាបន្ថែមសម្រាប់បុគ្គលដែលមានប្រព័ន្ធភាពស៊ាំខ្សោយ។

## 5. តើខ្ញុំចាំបាច់ត្រូវធ្វើអ្វីខ្លះ ប្រសិនបើមានការប៉ះពាល់នឹងមេរោគនៅទីតាំងមើលថែទាំកុមារលក្ខណៈគ្រួសាររបស់ខ្ញុំ?

- **ដាក់ឱ្យនៅដាច់ដោយឡែកពីគេ៖** ត្រូវតែដាក់ករណីមួយ(ឬច្រើន)ឱ្យនៅដាច់ដោយឡែកពីគេ ដូចដែលបាន

ណែនាំនៅក្នុង សេចក្តីណែនាំនៃការដាក់ឱ្យនៅដាច់ដោយឡែកពីគេ របស់ DPH។

- **ធ្វើចត្តាឡីស័ក៖** រាល់បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធនឹងមនុស្សដែលមានជំងឺ COVID-19 គួរតែចាកចេញពីកន្លែងថែទាំកុមារលក្ខណៈគ្រួសារនេះជាបន្ទាន់ និងត្រូវអនុវត្តតាម សេចក្តីណែនាំសម្រាប់ការធ្វើចត្តាឡីស័ក។ ពិនិត្យឡើងវិញឱ្យបានទៀងទាត់នូវ ផែនការគ្រប់គ្រងផលប៉ះពាល់នៅក្នុងមណ្ឌលថែទាំ និងអប់រំកុមារតូច សម្រាប់និយមន័យនៃបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធ និងសេចក្តីណែនាំសម្រាប់ការធ្វើចត្តាឡីស័ក នៅក្នុងវិស័យអប់រំដែលថ្មីបំផុត។
- **សម្អាត/សម្លាប់មេរោគនៅក្នុងទីតាំងរបស់អ្នកដូចដែលបានពិពណ៌នានៅក្នុងប្រភពឯកសារ #5 ខាងក្រោម។**
- **រាយការណ៍ដូចដែលបានពិពណ៌នានៅក្នុងផ្នែកទី 1 ខាងលើ។**
- **ប្រសិនបើមានមនុស្សដែលជា អ្នកប៉ះពាល់ឬអ្នកឆ្លងមេរោគ ហើយជាអ្នកដែលអាស្រ័យនៅក្នុងទីតាំងមើលថែទាំកុមារនេះ សូមបិទទ្វារទីកន្លែងនោះជាបណ្តោះអាសន្ន៖** ទីតាំងនេះត្រូវតែបិទទ្វារខណៈពេលដែលមនុស្សគ្រប់គ្នាដែលរស់នៅក្នុងទីតាំងមើលថែទាំកុមារនោះ កំពុងស្ថិតនៅដាច់ដោយឡែកពីគេ ឬធ្វើចត្តាឡីស័ក។ ទីតាំងនេះអាចនឹងបើកដំណើរការឡើងវិញបាន បន្ទាប់ពីអ្នករាល់គ្នាដែលរស់នៅក្នុងទីតាំងមើលថែទាំកុមារនេះ បានបញ្ចប់រយៈពេលនៃការដាក់ឱ្យនៅដាច់ដោយឡែកពីគេ ឬធ្វើចត្តាឡីស័កដែលបានតម្រូវ។ បុគ្គលិក និងកុមារដែលមិនមែនជាអ្នកដែលអាស្រ័យនៅទីតាំងនេះ ក៏ត្រូវតែបញ្ចប់ការដាក់ឱ្យស្ថិតនៅដាច់ដោយឡែកពីគេ ឬធ្វើចត្តាឡីស័ករៀងៗខ្លួនផងដែរ មុនពេលត្រលប់មកទីតាំងនោះវិញ។

### 6. តើខ្ញុំត្រូវបិទទ្វារទីតាំងមើលថែទាំកុមារលក្ខណៈគ្រួសាររបស់ខ្ញុំនៅពេលណា?

**ទីតាំងមើលថែទាំកុមារត្រូវតែបិទទ្វារនៅក្នុងស្ថានភាពទាំងអស់ដូចខាងក្រោមនេះ។** ទីតាំងមើលថែទាំកុមារនេះត្រូវតែបិទទ្វារ ខណៈពេលដែលមនុស្សគ្រប់គ្នាដែលរស់នៅក្នុងទីតាំងមើលថែកុមារនោះ ត្រូវដាក់ឱ្យស្ថិតនៅដាច់ដោយឡែកពីគេ ឬធ្វើចត្តាឡីស័ក។ លើសពីនេះទៀត រាល់តម្រូវការដែលមានចែងក្នុងផ្នែកទី 5 ត្រូវអនុវត្ត។

- **ស្ថានភាពទី 1៖** ប្រសិនបើកុមារ ឬបុគ្គលិកដែលបានបញ្ជាក់ថាមានមេរោគនៃជំងឺ COVID-19 ស្ថិតនៅក្នុងទីតាំងមើលថែទាំកុមាររបស់អ្នក ក្នុងអំឡុងពេល *អាចចម្លងមេរោគបាន* របស់ពួកគេដូចដែលបានកំណត់ខាងលើនោះ ពួកគេប្រហែលជាធ្វើឱ្យអ្នកដទៃដែលនៅទីកន្លែងនោះ ប៉ះពាល់នឹងមេរោគផងដែរ។ ប្រសិនបើអ្នកផ្តល់សេវាកម្មថែទាំកុមារមិនអាចកំណត់បានថា តើកុមារនិងបុគ្គលិកណាជាមនុស្សដែលមានទំនាក់ទំនងជិតស្និទ្ធនោះ កុមារនិងបុគ្គលិកទាំងអស់គួរតែអនុវត្តតាមសេចក្តីណែនាំសម្រាប់ការធ្វើចត្តាឡីស័ក។
- **ស្ថានភាពទី 2៖** ប្រសិនបើអ្នកណាម្នាក់ដែលរស់នៅក្នុងទីតាំងមើលថែទាំកុមារ**ធ្វើតេស្តទទួលលទ្ធផលវិជ្ជមាន**នោះ ទីតាំងមើលថែទាំកុមារនោះត្រូវតែបិទទ្វារ។ អ្នកផ្តល់សេវាកម្មថែទាំកុមារក៏ត្រូវកំណត់ថា តើនរណាម្នាក់គឺជាបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធនឹងករណីនេះ ហើយណែនាំឱ្យគេធ្វើចត្តាឡីស័ក។ ប្រសិនបើអ្នកផ្តល់សេវាកម្មមិនអាចបញ្ជាក់ថាមានការប៉ះពាល់នឹងមេរោគនៅក្នុងទីតាំងមើលថែទាំកុមារ ប៉ុន្តែមិនអាចកំណត់អត្តសញ្ញាណអ្នកដែលមានទំនាក់ទំនងជិតស្និទ្ធឱ្យបានច្បាស់លាស់ទេនោះ កុមារនិងបុគ្គលិកទាំងអស់ត្រូវតែធ្វើចត្តាឡីស័ក។ អ្នកផ្តល់សេវាកម្មថែទាំកុមារត្រូវបានតម្រូវឱ្យរាយការណ៍អំពីករណីនេះទៅ DPH ដូចដែលបានពិពណ៌នានៅក្នុងផ្នែកទី 1 ខាងលើ។
- **ស្ថានភាពទី 3៖** ប្រសិនបើមាននរណាម្នាក់ដែលរស់នៅក្នុងទីតាំងមើលថែទាំកុមារលក្ខណៈគ្រួសារនេះ បានប៉ះពាល់នឹងមេរោគ (ត្រូវបានចាត់ទុកថាជាបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធ) ហើយត្រូវបានតម្រូវឱ្យនៅដាច់ដោយឡែកដូចដែលបានបង្គាប់ក្នុង សេចក្តីណែនាំឱ្យធ្វើចត្តាឡីស័ក ទីតាំងនោះត្រូវតែបិទទ្វារជាបណ្តោះអាសន្ន។

### 7. តើខ្ញុំមិនចាំបាច់បិទទ្វារទីតាំងថែទាំកុមារលក្ខណៈគ្រួសាររបស់ខ្ញុំនៅពេលណា?

អ្នកមិនចាំបាច់ត្រូវបិទទ្វារទីតាំងថែទាំកុមារលក្ខណៈគ្រួសាររបស់អ្នកទេ ប្រសិនបើកុមារ ឬបុគ្គលិក**ដែលមិនរស់នៅក្នុងទីតាំងថែទាំកុមារ** បានប៉ះពាល់ទៅនឹងជំងឺ COVID-19 នៅខាងក្រៅទីតាំងថែទាំកុមារនោះ។ បុគ្គលនេះត្រូវបានគេចាត់ទុកថាជាមនុស្សដែលមានទំនាក់ទំនងជិតស្និទ្ធ ហើយត្រូវតែអនុវត្តតាមសេចក្តីណែនាំឱ្យធ្វើចត្តាឡីស័ក រួមទាំងការមិនរាប់បញ្ចូលនៅក្នុងទីតាំងថែទាំកុមាររបស់អ្នកដែរ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើកុមារឬបុគ្គលិកដែលបានប៉ះពាល់នឹងមេរោគ ធ្វើតេស្តទទួលបានលទ្ធផលវិជ្ជមានក្នុងអំឡុងពេលនៃការធ្វើចត្តាឡីស័ករបស់ពួកគេ

**ហើយ**ពួកគេបានស្ថិតនៅក្នុងទីតាំងថែទាំងកុមាររបស់អ្នកក្នុងអំឡុងពេលដែលអាចចម្លងមេរោគបាន នោះគួរអនុវត្តតាមផ្នែកទី 6 ស្ថានភាព #1 និងជំហានទាំងអស់នៅក្នុងផ្នែកទី 5។

អ្នកក៏មិនចាំបាច់ត្រូវបិទទ្វារទីតាំងរបស់អ្នកទេ ប្រសិនបើសមាជិកក្រុមគ្រួសារ និង/ឬបុគ្គលិក**ទាំងអស់** បានទទួលថ្នាំបង្ការពេញលេញ ដូចមានចែងក្នុងផ្នែកទី 4។

### ឯកសារណែនាំ ប្រភពឯកសារ និងពិធីការដើម្បីពិនិត្យនិងអនុវត្តតាម៖

1. សៀវភៅណែនាំស្តីពីការថែទាំ និងអប់រំកុមារតូចទាក់ទងនឹងជំងឺ COVID-19៖ នេះគឺជាទំព័រគោលដៅ (landing page) សម្រាប់ការអប់រំកុមារតូច (ECEs)។ ទំព័រនេះមានប្រភពឯកសារពាក់ព័ន្ធទាំងអស់ សម្រាប់វិស័យរបស់អ្នករួមទាំង វីឌីអូ (video) បង្ហាត់បង្ហាញអំពីរបៀបបញ្ជូនរបាយការណ៍តាមអ៊ិនធរណេតនិង វីឌីអូ (video) អំពីរបៀបនៃការបំពេញនូវតារាងបញ្ជីករណី និងអ្នកដែលមានទំនាក់ទំនងជាទ្រង់ទ្រាយអ៊ិចសែល (Excel)។ ខាងក្រោមនេះគឺជាបណ្តាញភ្ជាប់នានាទៅនឹងឯកសារសំខាន់ៗដែលអ្នកអាចចូលប្រើពីសៀវភៅណែនាំនេះបាន។
2. ឯកសារណែនាំស្តីពីការអប់រំកុមារតូច៖ សេចក្តីសង្ខេបនៃតម្រូវការចាំបាច់ និងគំរូអនុវត្តល្អៗបំផុតសម្រាប់អ្នកផ្តល់សេវាកម្មអប់រំកុមារតូច (ECE) ដើម្បីបង្កើនសុវត្ថិភាព និងបន្ថយហានិភ័យនៃការចម្លងជំងឺ COVID-19 នៅក្នុងទីតាំងអប់រំកុមារតូច (ECE) ផ្សេងៗ។
3. ផែនការគ្រប់គ្រងការប៉ះពាល់មេរោគក្នុងទីតាំងមើលថែទាំ និងអប់រំកុមារតូច៖ ឯកសារនេះបង្ហាញអ្នកអំពីជំហានដែលត្រូវការចាំបាច់ និងដែលបានណែនាំឱ្យអនុវត្ត នៅពេលដែលអ្នកមានករណីជំងឺ COVID-19 ច្បាស់លាស់ក្នុងទីតាំងថែទាំកុមាររបស់អ្នក។
4. វិធីសាស្ត្រសម្រេចចិត្តសម្រាប់ការប៉ះពាល់ និងត្រួតពិនិត្យជំងឺសម្រាប់កុមារ និងបុគ្គលិកនៅតាមគ្រឹះស្ថានអប់រំ ឯកសារនេះបង្ហាញអ្នកនូវអ្វីដែលអ្នកត្រូវធ្វើ ប្រសិនបើកុមារ/បុគ្គលិកម្នាក់ ទទួលលទ្ធផលវិជ្ជមានសម្រាប់ការពិនិត្យរោគសញ្ញា។
5. ការសម្អាតនៅក្នុងផ្ទះ
6. មានការណែនាំឱ្យបុគ្គលណាដែលត្រូវការធ្វើតេស្តរកមេរោគ COVID-19 ត្រូវទាក់ទងបន្តជាមួយអ្នកផ្តល់សេវាកម្មថែទាំសុខភាពបឋម (primary healthcare provider) របស់ពួកគេ។ ប្រសិនបើនេះមិនមែនជាជម្រើសដែលអាចធ្វើបានទេ សូមចូលទៅកាន់គេហទំព័រ៖ https://corona-virus.la/covid-19-testing សម្រាប់ព័ត៌មានអំពីការធ្វើតេស្ត និងដើម្បីកំណត់ពេលណាត់ជួបធ្វើតេស្ត។
7. សម្រាប់ព័ត៌មានបន្ថែមអំពីការចាក់ថ្នាំបង្ការជំងឺ COVID-19 និងដើម្បីចុះឈ្មោះសម្រាប់ការណាត់ជួប សូមចូលទៅកាន់គេហទំព័រ VaccinateLACounty.com។

ដើម្បីទទួលបានព័ត៌មានបន្ថែមអំពីជំងឺកូរ៉ូណាប្រភេទថ្មី (COVID-19) ឬសម្រាប់បច្ចុប្បន្នភាពថ្មីបំផុតសម្រាប់ LAC-DPH និងបទបញ្ជាមន្ត្រីសុខាភិបាលដែលពាក់ព័ន្ធនឹងជំងឺ COVID-19 សូមចូលទៅកាន់គេហទំព័រ DPH website។ សូមទាក់ទងមកកាន់អ៊ីម៉ែល ACDC-Education@ph.lacounty.gov សម្រាប់សំណួរអំពីការគ្រប់គ្រងការប៉ះពាល់នឹងមេរោគណាមួយ។

**ប្រសិនបើអ្នកមិនអាចបញ្ជូនរបាយការណ៍ទៅ DPH តាមរយៈគេហទំព័រ REDCap ហើយមានបំណងបញ្ជូនរបាយការណ៍តារាងបញ្ជីករណី និងអ្នកដែលមានទំនាក់ទំនងរបស់អ្នកជាទ្រង់ទ្រាយអ៊ិចសែល (Excel) តារាងអ៊ិចសែលនោះត្រូវមានការការពារដោយពាក្យសម្ងាត់។**
**សេចក្តីណែនាំមានដូចខាងក្រោម៖**

**ដាក់ពាក្យសម្ងាត់ការពារតារាងបញ្ជីករណី និងអ្នកដែលមានទំនាក់ទំនង - សេចក្តីណែនាំ**

**ដើម្បីការពារព័ត៌មានសុខភាពផ្ទាល់ខ្លួន (PHI) ដែលមាននៅក្នុងតារាងបញ្ជីករណី និងអ្នកដែលមានទំនាក់ទំនងជាទ្រង់ទ្រាយអ៊ិចសែលនេះ សៀវភៅការងារអ៊ិចសែល ត្រូវតែមានការការពារដោយពាក្យសម្ងាត់៖**

1. សម្រាប់កំព្យូទ័រប្រើប្រាស់ប្រព័ន្ធ Windows សូមចុច “ឯកសារ” (“File”) > “ព័ត៌មាន” (“Info”) នៅផ្នែកខាងឆ្វេង។
2. ចុច “ការពារសៀវភៅការងារ” (“Protect Workbook”) បន្ទាប់មកចុច “ការពារព័ត៌មានដោយប្រើលេខសម្ងាត់” (“Encrypt with Password”)
3. វាយបញ្ចូលពាក្យសម្ងាត់របស់អ្នក ចុចយល់ព្រម (“OK”) ហើយវាយពាក្យសម្ងាត់នោះម្តងទៀត។ រក្សា (“Save”) ឯកសារទុក។
4. នៅក្នុងអ៊ីម៉ែលដាច់ដោយឡែកពីគ្នា ផ្ញើពាក្យសម្ងាត់ទៅ ACDC-education@ph.lacounty.gov។ ផ្ញើឯកសារអ៊ិចសែលនេះនៅក្នុងអ៊ីម៉ែលមួយផ្សេងទៀត។
5. សម្រាប់កំព្យូទ័រប្រើប្រាស់ប្រព័ន្ធ Mac សូមចុច “ឯកសារ” (“File”) បន្ទាប់មក “ពាក្យសម្ងាត់” (“Passwords”)
6. វាយបញ្ចូលពាក្យសម្ងាត់ក្នុងចន្លោះ “ពាក្យសម្ងាត់ដើម្បីបើក” (“Password to Open”)។ សូមប្រាកដថា ចំណុច “បានណែនាំសម្រាប់តែអាន” (“Read-only Recommended”) មិនត្រូវបានចុចធីកទេ។ ចុចលើពាក្យយល់ព្រម (“OK”)។ វាយលេខសម្ងាត់ម្តងទៀត និងចុចលើពាក្យយល់ព្រម (“OK”)។ រក្សា (“Save”) ឯកសារទុក។
7. នៅក្នុងអ៊ីម៉ែលដាច់ដោយឡែកពីគ្នា ផ្ញើពាក្យសម្ងាត់ទៅ ACDC-education@ph.lacounty.gov។ ផ្ញើឯកសារអ៊ិចសែលនេះនៅក្នុងអ៊ីម៉ែលមួយផ្សេងទៀត។